# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ**...៨១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរអាងទន្លេសាប

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៧/៤១២ ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៧ ស្តីពីការបង្កើតអាជ្ញាធរអាងទន្លេសាប
- បានឃើញអនុក្រឹត្យលេខ ៤៩ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរអាងទន្លេសាប
- តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា មួយ.-**

មាត្រា៣ នៃអនុក្រឹត្យលេខ៤៩ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរអាងទន្លេសាប (អ.អ.ទ.ស) ត្រូវបានកែសម្រួលដូចខាងក្រោម ÷

**មាត្រា ៣ ថ្មី.-**

អគ្គលេខាធិការដ្ឋាននៃ អ.អ.ទ.ស មានរចនាសម្ព័ន្ធ ដូចខាងក្រោម ÷

១- នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

២- នាយកដ្ឋានផែនការ និងសហប្រតិបត្តិការ

៣- នាយកដ្ឋានសម្របសម្រួលគម្រោងផែនសេដ្ឋកិច្ច

៤- នាយកដ្ឋានសម្របសម្រួលគម្រោងផែនសង្គមកិច្ច

៥- នាយកដ្ឋានធនធានធម្មជាតិ និងបរិស្ថាន

៦- នាយកដ្ឋានស្រាវជ្រាវ និងផ្សព្វផ្សាយព័ត៌មាន

នាយកដ្ឋាននីមួយៗ ត្រូវដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយការតាមការចាំបាច់។

អគ្គលេខាធិការដ្ឋាននៃ អ.អ.ទ.ស មានក្រុមបង្គោលអាជ្ញាធរអាងទន្លេសាប ប្រចាំរាជធានី ខេត្តពាក់ព័ន្ធ។

អង្គការលេខរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរអាងទន្លេសាប ជាឧបសម្ព័ន្ធរបស់អនុក្រឹត្យនេះ ។

**មាត្រា ពីរ.-**

នាយកដ្ឋានធនធានធម្មជាតិ និងបរិស្ថាន មានតួនាទី និងភារកិច្ច ÷

- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ កម្មវិធី គម្រោង និងផែនការសកម្មភាព ដើម្បីការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់អាងទន្លេសាប ក្នុងបរិបទធនធានធម្មជាតិ និងបរិស្ថាន សម្រាប់រយៈពេលខ្លី មធ្យម និងវែង ដោយមានកិច្ចសហការជាមួយបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍ
- ចូលរួម និងសម្របសម្រួលជាមួយក្រសួង ស្ថាប័នជំនាញក្នុងផ្នែកធនធានធម្មជាតិ និងបរិស្ថាន ក្នុងការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ កម្មវិធី និងគម្រោងនានា ដើម្បីការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់អាងទន្លេសាប
- លើកកម្ពស់ការយល់ដឹងអំពីភាពចាំបាច់ សារៈសំខាន់ និងតម្លៃនៃធនធានធម្មជាតិ និងបរិស្ថានក្នុងតំបន់អាងទន្លេសាប ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍនានា
- តាមដានត្រួតពិនិត្យ និងវាយតម្លៃពីផលប៉ះពាល់នៃការអនុវត្តគម្រោង ដែលពាក់ព័ន្ធដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍធនធានធម្មជាតិ និងបរិស្ថាន ដែលបាន និងកំពុងដំណើរការក្នុងដែនសមត្ថកិច្ចរបស់ អ.អ.ទ.ស តាមតម្រូវការជាក់ស្តែង
- សម្របសម្រួលការអនុវត្តគម្រោងគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍធនធានធម្មជាតិ និងបរិស្ថាន របស់បណ្តាក្រសួង ស្ថាប័នជំនាញ និងដៃគូអភិវឌ្ឍ ដើម្បីភាពរលូន ភាពប្រទាក់ក្រឡាគ្នា ក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់អាងទន្លេសាបតាមការចាំបាច់
- សិក្សា និងអនុវត្តគម្រោងសាកល្បង ដើម្បីការងារគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍធនធានធម្មជាតិ និងបរិស្ថានក្នុងតំបន់អាងទន្លេសាប តាមការចាំបាច់
- រាយការណ៍ពីវឌ្ឍនភាពការងារក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍធនធានធម្មជាតិ និងបរិស្ថានក្នុងតំបន់អាងទន្លេសាប ជូន អ.អ.ទ.ស តាមកាលកំណត់
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការ អ.អ.ទ.ស ប្រគល់ជូន ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានអាជ្ញាធរអាងទន្លេសាប រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**<u>កន្លែងទទួល</u> :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ...៨១...អនក្រ.បក ចុះថ្ងៃទី ២៧...ខែ ឧសភា....ឆ្នាំ២០០៩**

**អង្គការលេខរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរអាងទន្លេសាប**

